ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

## បែបបទ និងនិតិវិធីសម្រាប់ការដាក់ពាក្យចូលរៀនវគ្គបណ្តុះបណ្តាល ចំពោះអ្នកដែលមានបំណងធ្វើជាអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម

ដើម្បីសម្រួលដល់ការស្នើសុំក្នុងការដាក់ពាក្យចូលរៀនវគ្គបណ្តុះបណ្តាលនេះ ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូននូវបែបបទ និងនិតិវិធីសម្រាប់ការដាក់ពាក្យដូចខាងក្រោមៈ

១. អ្នកដាក់ពាក្យអាចដាក់ពាក្យស្នើសុំចូលរៀនចាប់ពីម៉ោង ៨: ៣០ រហូតដល់ម៉ោង ១១: ៣០នាទីព្រឹក និង ម៉ោង ១៤: ០០ រសៀល រហូតដល់ម៉ោង ១៧: ០០ ល្ងាច ដែលកន្លែងទទួលពាក្យស្នើសុំចូលរៀននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម

២. នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នឹងទទួលពាក្យស្នើសុំ ដែលបានបំពេញត្រឹមត្រូវ និងមានឯកសារតម្រូវគ្រប់គ្រាន់ ចំនួន ២៥នាក់ ក្នុងមួយថ្ងៃ

៣. អ្នកដាក់ពាក្យស្នើសុំអាចមកចាប់យកលេខរៀងដែលមានចំនួន ២៥លេខ ក្នុងមួយថ្ងៃ ហើយការចាប់លេខរៀងនឹងប្រព្រឹត្ត ទៅពីម៉ោង ៧: ៣០នាទីព្រឹក ជារៀងរាល់ថ្ងៃ

៤. អ្នកដែលទទួលបានលេខរៀងអាចដាក់ពាក្យស្នើសុំសម្រាប់តែថ្ងៃដែលបានកំណត់ក្នុងលេខតែប៉ុណ្ណោះ

៥. ការទទួលពាក្យនឹងដំណើរការតាមនិតិវិធីខាងលើជារៀងរាល់ថ្ងៃនៃថ្ងៃធ្វើការ ហើយត្រូវបញ្ចប់នៅពេលដែលការទទួលពាក្យបានគ្រប់ចំនួន ៧០នាក់ដំបូង។

អាស្រ័យហេតុនេះ ចំពោះសាធារណជនមានចំណាប់អារម្មណ៍លើវគ្គបណ្តុះបណ្តាលខាងលើនេះ សូមអញ្ជើញប្រញាប់មកដាក់ពាក្យស្នើសុំចូលរៀន ព្រោះកន្លែងមានកំណត់។